**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ....៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលសមាសភាព និងការប្រព្រឹត្តទៅ

## នៃគណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត គណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទ

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ :** កែសំរួលសមាសភាព និងការប្រព្រឹត្តិទៅនៃ **គណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទ** ដែលសរសេរកាត់ថា «**គជឥអ**» ។

**មាត្រា ២** : សមាសភាពថ្មីរបស់ **គជនាន** មានដូចខាងក្រោម :

| | | |
|---|---|---|
| ១. | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាប្រធាន |
| ២. | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាអនុប្រធាន |
| ៣. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៤. | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៥. | តំណាងក្រសួងកិច្ចការនារី | ជាសមាជិក |
| ៦. | តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៧. | តំណាងឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | ជាសមាជិក |
| ៨. | តំណាងធនាគារអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៩. | តំណាងសមាគមធនាគារកម្ពុជា | ជាសមាជិក |
| ១០. | តំណាងសមាគមស្ថាប័នមីក្រូហិរញ្ញវត្ថុកម្ពុជា | ជាសមាជិក |
| ១១. | តំណាងសហគមន៍អភិវឌ្ឍន៍កសិកម្ម | ជាសមាជិក |
| ១២. | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាលេខាធិការ |

**មាត្រា ៣** : សមាជិកទាំងអស់ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន **គជនាន** ដែលត្រូវធ្វើការប្រជុំយ៉ាងតិច ២ ដង ក្នុងមួយឆ្នាំ ។ ក្នុងករណីចាំបាច់ប្រធាន **គជនាន** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នជាតិ និង ស្ថាប័នអន្តរជាតិពាក់ព័ន្ធ ឬ អ្នកជំនាញផ្សេងទៀត ដើម្បីចូលរួមប្រជុំជាមួយ ។

**មាត្រា ៤** : **គជនាន** មានភារកិច្ចដូចខាងក្រោម :

**១.** រៀបចំ និង អនុម័តក្របខ័ណ្ឌយុទ្ធសាស្ត្រ និង គោលនយោបាយជាតិ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ សំរាប់ការអភិវឌ្ឍន៍ជនបទ ។

**២.** ជំរុញ និង តាមដានការអនុវត្តយុទ្ធសាស្ត្រ និង គោលនយោបាយជាតិ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

៣. សំរបសំរួលការប្រើប្រាស់ និង ការអនុវត្តន៍គំរោងឥណទាន សំរាប់ការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុ ដែលទទួលបានហិរញ្ញប្បទានពីរាជរដ្ឋាភិបាល ពីស្ថាប័នហិរញ្ញវត្ថុជាតិ និង អន្តរជាតិ ពីប្រទេសជាមិត្ត និង ពីប្រភពឥណទានផ្សេងទៀត ដើម្បីធានាឱ្យការប្រើប្រាស់ឥណទានទាំងនេះ ស្របទៅតាមយុទ្ធសាស្ត្រ និង គោលនយោបាយជាតិ ដែលបានកំណត់ ។

៤. តាមដានការផ្តល់ឥណទាន ឬ ធនធាន របស់ស្ថាប័ន ឬប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ដែលមានអាជ្ញាប័ណ្ណឬចុះបញ្ជី នៅធនាគារជាតិនៃកម្ពុជា ព្រមទាំងប្រតិបត្តិករផ្សេងទៀតដែលធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ដោយមិនទាន់បានចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាឱ្យបាននូវប្រសិទ្ធិភាព និង និរន្តភាពនៃហិរញ្ញប្បទានលើវិស័យនេះ ។

៥. រៀបចំកម្មវិធី និង ផែនការសកម្មភាព ដើម្បីអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ រួមមានការគៀងគរជំនួយពីបរទេស ជាទ្វេភាគី និង ពហុភាគី សំរាប់តំរូវការឥណទានជនបទ ព្រមទាំងជំរុញឱ្យស្ថាប័នហិរញ្ញវត្ថុក្នុងស្រុកចូលរួមចំណែកគាំទ្រដល់ការអភិវឌ្ឍន៍វិស័យឥណទានជនបទ នៅកម្ពុជា ។

៦. ចូលរួមក្នុងការកសាងសមត្ថភាពស្ថាប័នគ្រប់គ្រង និង សមត្ថភាពប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ តាមរយៈការរៀបចំសិក្ខាសាលាជាតិ-អន្តរជាតិ និង ការស្វែងរកជំនួយផ្សេងៗ ដើម្បីពង្រឹងសមត្ថភាពលើវិស័យនេះ ។

៧. បំពេញភារកិច្ចផ្សេងទៀត ដែលគណកម្មាធិការនេះយល់ថាចាំបាច់ ក្នុងទិសដៅជំរុញដល់ការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ។

**មាត្រា ៥ :** លេខាធិការដ្ឋានរបស់ **គជឥជ** ត្រូវបង្កើតឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីធ្វើជាសេនាធិការឱ្យ **គជឥជ** ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ លេខាធិការដ្ឋានអាចទទួលជំនួយបច្ចេកទេស និង ជំនួយផ្សេងៗទៀត ពីអង្គការ/ស្ថាប័នហិរញ្ញវត្ថុជាតិ និង អន្តរជាតិ និងពីប្រទេសជាមិត្ត ដើម្បីជួយដល់ដំណើរការការងារ

របស់ខ្លួន និង សំរាប់កម្មវិធីអភិវឌ្ឍន៍មីក្រូហិរញ្ញវត្ថុ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៦ :** មុខងារ និង ភារកិច្ច របស់លេខាធិការដ្ឋាន **គវអជ** ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ លេខាធិការដ្ឋាន **គវអជ** អាចជ្រើសរើសបុគ្គលិកពីវិស័យឯកជន មកបំរើការងារជាលក្ខណៈមន្ត្រីជាប់កិច្ចសន្យា ដោយមានការឯកភាពពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៧ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាជិកទាំងអស់នៃគណៈកម្មាធិការវេណទានសំរាប់អភិវឌ្ឍន៍ជនបទ ដូចមានសមាសភាព ចែងក្នុងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តខ្លឹមសារនៃអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមានក្នុងមាត្រា ៨
- ឯកសារ-កាលប្បវត្តិ